# ព្រះរាជក្រម

នស/រកម/១២១៩/០២០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី២ស្តីពីការកំណត់ច្រកទ្វារព្រំដែនឆ្លងកាត់នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីកិច្ចសម្របសម្រួលការដឹកជញ្ជូនទំនិញឆ្លងកាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៤ខែវិច្ឆិកាឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ខែវិច្ឆិកា ឆ្នាំ២០១៩ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើពិធីសារទី២ ស្តីពីការកំណត់ច្រកទ្វារព្រំដែនឆ្លងកាត់នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីកិច្ចសម្របសម្រួលការដឹកជញ្ជូនទំនិញឆ្លងកាត់

**មាត្រា១.-**

អនុម័តយល់ព្រមលើពិធីសារទី ២ ស្តីពីការកំណត់ច្រកទ្វារព្រំដែនឆ្លងកាត់នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីកិច្ចសម្របសម្រួលការដឹកជញ្ជូនទំនិញឆ្លងកាត់ ដែលព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខានៅទីក្រុងកាវ៉ៃនៃប្រទេសម៉ាឡេស៊ី នាថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៨ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

**មាត្រា៣.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃ ព្រហស្បតិ៍ ៧ កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១៩

នស.រកម.១២១៩.០២១

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ពិធីសារទី២
# ស្តីពីការកំណត់ច្រកទ្វារព្រំដែនឆ្លងកាត់

រដ្ឋាភិបាលនៃព្រុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ដែលហៅថា "បណ្តាប្រទេសហត្ថលេខី" ឬតែមួយហៅថា "ប្រទេសហត្ថលេខី")។

**ដោយរំលឹកឡើងវិញ** កិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្តីពីកិច្ចសម្របសម្រួលការដឹកជញ្ជូនទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខានៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៨ នៅទីក្រុងហាណូយ ប្រទេសវៀតណាម( សំដៅលើ "កិច្ចព្រមព្រៀង")។

**ដោយទទួលស្គាល់**មាត្រា៧និងមាត្រា២៥ ផ្តល់ការសន្មត់នៃការអនុវត្តពិធីសារនានា ដែលត្រូវជាផ្នែករបស់កិច្ចព្រមព្រៀងនេះ។

**ដោយមានគោលបំណង** លើកទឹកចិត្តនិងសម្រួលប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់និងដឹកជញ្ជូនអន្តររដ្ឋនៅក្នុងចំណោមប្រទេសហត្ថលេខី។

**ដោយឯកភាពបញ្ជាក់ថា** ការបញ្ចប់ពិធីសារនេះនឹងផ្តល់ការរៀបចំប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពដល់ពាណិជ្ជកម្មដឹកជញ្ជូនឆ្លងកាត់ក្នុងបណ្តាប្រទេសហត្ថលេខី។

**បានព្រមព្រៀងដូចតទៅនេះ៖**

## មាត្រា១

## វិសាលភាពនៃការអនុវត្ត

១. យោងតាមកថាខណ្ឌទី១ មាត្រា៧ នៃកិច្ចព្រមព្រៀង បណ្តាប្រទេសហត្ថលេខីព្រមព្រៀងគ្នាអនុវត្តបញ្ញត្តិនៃពិធីសារនេះ ដើម្បីកំណត់ច្រកទ្វារព្រំដែនឆ្លងកាត់សម្រាប់ត្រួតពិនិត្យនិងបំពេញបែបបទគយលើមធ្យោបាយដឹកជញ្ជូននិងទំនិញឆ្លងកាត់។

២. ដោយផ្អែកលើការព្រមព្រៀងគ្នារវាងប្រទេសហត្ថលេខីជិតខាងមួយ ឬច្រើន បណ្តាប្រទេសហត្ថលេខីអាចអនុញ្ញាតឲ្យមានការត្រួតពិនិត្យនិងបំពេញបែបបទគយលើមធ្យោបាយដឹកជញ្ជូននិងទំនិញឆ្លងកាត់ នៅច្រកទ្វារព្រំដែនផ្សេងទៀត បន្ថែមលើច្រកទ្វារព្រំដែនឆ្លងកាត់ដែលបានកំណត់សម្រាប់ករណីលើកលែងឬបណ្តោះអាសន្ន ប្រសិនបើលក្ខខណ្ឌនានាត្រូវបានបំពេញដោយមានសង្គតិភាពជាមួយគោលការណ៍នានាដែលមានចែងក្នុងកិច្ចព្រមព្រៀង និងពិធីសារនេះ។

## មាត្រា២

## ការកំណត់ច្រកទ្វារព្រំដែនឆ្លងកាត់

១. បណ្តាប្រទេសហត្ថលេខីព្រមព្រៀងគ្នាបង្កើតច្រកទ្វារព្រំដែនបឋមរបស់ខ្លួនសម្រាប់ជាមូលដ្ឋានដើម្បីកំណត់ច្រកទ្វារព្រំដែនឆ្លងកាត់ សម្រាប់គោលបំណងនៃពិធីសារនេះដែលមានចែងក្នុងឧបសម្ព័ន្ធនៃពិធីសារនេះ។

២. បណ្តាប្រទេសហត្ថលេខីត្រូវបញ្ជាក់ច្រកទ្វារព្រំដែនឆ្លងកាត់ដែលខ្លួនកំណត់នៅពេលតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ននៅអគ្គលេខាធិការអាស៊ាន។ ការកំណត់ច្រកទ្វារព្រំដែនឆ្លងកាត់ ត្រូវផ្អែកលើការឯកភាពគ្នាទៅវិញទៅមក រវាងប្រទេសហត្ថលេខីជាប់ព្រំដែនមួយឬច្រើន។

៣. បណ្តាប្រទេសហត្ថលេខីអាចស្នើកែសម្រួលបញ្ជីច្រកទ្វារព្រំដែនឆ្លងកាត់ពីពេលមួយទៅពេលមួយ។ រាល់សំណើកែសម្រួលរបស់ប្រទេសហត្ថលេខីមួយត្រូវផ្អែកលើការឯកភាពគ្នាទៅវិញទៅមករវាងបណ្តាប្រទេសហត្ថលេខីជាប់ព្រំដែនមួយឬច្រើន។ ការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធបញ្ជីច្រកទ្វារព្រំដែនឆ្លងកាត់ ត្រូវដាក់តម្កល់នៅអគ្គលេខាធិការអាស៊ាន ដែលជាអ្នកត្រូវជូនដំណឹងជាបន្ទាន់ទៅបណ្តាប្រទេសហត្ថលេខីពីការកែសម្រួលនេះ។

៤. ច្រកទ្វារព្រំដែនឆ្លងកាត់ ដែលអនុលោមតាមពិធីសារនេះ មិនត្រូវពាក់ព័ន្ធដល់ដែនដីដែលកំពុងមានវិវាទរវាងបណ្ដាប្រទេសហត្ថលេខី។

## មាត្រា ៣

## ស្ថាប័នចាត់ចែង

១.កិច្ចប្រជុំអគ្គនាយកគយអាស៊ាន ត្រូវទទួលខុសត្រូវនូវការត្រួតពិនិត្យ ពិនិត្យឡើងវិញ សម្របសម្រួល និងគ្រប់គ្រងគ្រប់ទិដ្ឋភាពពាក់ព័ន្ធនឹងការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃពិធីសារនេះ។

២.លេខាធិការដ្ឋានអាស៊ានចាំបាច់ ត្រូវផ្ដល់ជំនួយនិងការគាំទ្រផ្នែករដ្ឋបាលសម្រាប់កិច្ចប្រជុំអគ្គនាយកគយអាស៊ាន ដើម្បីអនុវត្តភារកិច្ច និងបំពេញការទទួលខុសត្រូវ ក្រោមពិធីសារនេះ។

## មាត្រា៤

## អវសានប្បញ្ញត្តិ

១. ពិធីសារនេះត្រូវតម្កល់ទុកនៅអគ្គលេខាធិការអាស៊ាន ដែលជាអ្នកត្រូវបញ្ជូនជាបន្ទាន់នូវច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវមួយច្បាប់ឲ្យទៅប្រទេសហត្ថលេខីនីមួយៗ។

២.ពិធីសារនេះ គឺជាផ្នែកសំខាន់នៃកិច្ចព្រមព្រៀង។ ក្នុងករណីគ្មានសង្គតិភាព ឬមានជម្លោះ កិច្ចព្រមព្រៀងត្រូវយកជាគោល។

៣.ពិធីសារនេះ ត្រូវតែជាកម្មវត្ថុនៃការផ្ដល់សច្ចាប័ន ឬការទទួលយកដោយប្រទេសហត្ថលេខី។ លិខិតុបករណ៍នៃការផ្ដល់សច្ចាប័ន ឬការទទួលយក រួមទាំងការបញ្ជាក់ច្រកទ្វារព្រំដែនឆ្លងកាត់ត្រូវតម្កល់ទុកនៅអគ្គលេខាធិការអាស៊ាន ដែលជាអ្នកត្រូវជូនដំណឹងជាបន្ទាន់ទៅប្រទេសហត្ថលេខីនីមួយៗពីការតម្កល់ទុកនេះ។ ការបញ្ជាក់ ឬការកំណត់នៃច្រកទ្វារព្រំដែនឆ្លងកាត់ ឬការផ្លាស់ប្ដូរ និងការកែប្រែច្រកទ្វារព្រំដែនឆ្លងកាត់ជាបន្តបន្ទាប់ ត្រូវភ្ជាប់ជាមួយឯកសារគាំទ្រដែលបញ្ជាក់ពីការឯកភាពគ្នារវាងប្រទេសហត្ថលេខីជាប់ព្រំដែនមួយ ឬច្រើន។

៤. ពិធីសារនេះ ត្រូវចូលជាធរមានក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ បន្ទាប់ពីបណ្ដាប្រទេសហត្ថលេខីចំនួន៦(ប្រាំមួយ)បានតម្កល់លិខិតុបករណ៍នៃការផ្ដល់សច្ចាប័ន ឬការទទួល

យកពិធីសារនេះ និងត្រូវមានសុពលភាពសម្រាប់អនុវត្តតែក្នុងបណ្តាប្រទេសហត្ថលេខីដែលបានផ្តល់សច្ចាប័ន ឬទទួលយកពិធីសារនេះ ។ ប្រទេសហត្ថលេខីផ្សេងទៀតដែលផ្តល់សច្ចាប័នឬទទួលយកពិធីសារនេះក្រោយពេលនេះត្រូវមានសពុលភាពអនុវត្តក្នុងរយៈពេល៦០(ហុកសិប) ថ្ងៃបន្ទាប់ពីការតម្កល់លិខិតុបករណ៍ នៃការផ្តល់សច្ចាប័ន ឬការទទួលយកពិធីសារនេះ។

៥. គ្មានការបម្រុងទុកណាមួយត្រូវបានធ្វើឡើងសម្រាប់ពិធីសារនេះ ទាំងនៅពេលចុះហត្ថលេខា ឬការផ្តល់សច្ចាប័ន ឬការទទួលយកពិធីសារនេះទេ។

៦. លើកលែងតែការធ្វើវិសោធនកម្មចំពោះឧបសម្ព័ន្ធដែលមានចែងក្នុងកថាខណ្ឌទី៣ នៃមាត្រា២ នៃពិធីសារនេះ រាល់ការធ្វើវិសោធនកម្មបញ្ញត្តិណាមួយនៃពិធីសារនេះ ត្រូវតែមានការព្រមព្រៀងពីគ្រប់ប្រទេសហត្ថលេខីទាំងអស់។

**ដើម្បីជាសក្ខីភាព** ហត្ថលេខីខាងក្រោមដែលបានទទួលសិទ្ធប្រទានពីរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើពិធីសារទី២ស្តីពីការកំណត់ច្រកទ្វារព្រំដែនឆ្លងកាត់ ដើម្បីអនុវត្តកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្តីពីកិច្ចសម្រួលការដឹកជញ្ជូនទំនិញឆ្លងកាត់។

ធ្វើនៅឡាំងការី ប្រទេសម៉ាឡេស៊ី ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ ជាច្បាប់ដើមតែមួយជាភាសាអង់គ្លេស។

សម្រាប់រដ្ឋាភិបាលព្រុយណេដារូសាឡឹម

**តេហ៊ីន ដាតូ អាបរ៉ាម៉ាន អ៊ីប្រ៉ាហ៊ីម**
រដ្ឋមន្ត្រីនៃការិយាល័យនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីហិរញ្ញវត្ថុ ២

សម្រាប់រាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា

**ខួន សុខា**
រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូណេស៊ី

**ស្រ៊ី មូលយ៉ានី អ៊ីនដ្រាវ៉ាទី**
រដ្ឋមន្ត្រីហិរញ្ញវត្ថុ

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

**ស៊ីឡា វៀងកែវ**
អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ

សម្រាប់រដ្ឋាភិបាលម៉ាឡេស៊ី

**ដាតុក ស៊េរី ចូហារី អេបឌូល ហ្គានី**
រដ្ឋមន្ត្រីហិរញ្ញវត្ថុ ២

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា

**គីយ៉ាវ វីន**
រដ្ឋមន្ត្រីសហភាពនៃក្រសួងផែនការ និងហិរញ្ញវត្ថុ

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន

**ខាឡូស ជី. ដូមីងហ្គេស**
រដ្ឋមន្ត្រីហិរញ្ញវត្ថុ

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរី

**ឡរ៉េន វង់**
រដ្ឋមន្ត្រីទី២ នៃហិរញ្ញវត្ថុ

សម្រាប់រាជរដ្ឋាភិបាលព្រះរាជាណាចក្រថៃឡង់ដ៍

**អាតីស័ក តាន់ទីវរៈវង្ស**
រដ្ឋមន្ត្រីហិរញ្ញវត្ថុ

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម

**ឌីញ ទៀនឌុង**
រដ្ឋមន្ត្រីហិរញ្ញវត្ថុ

# ឧបសម្ព័ន្ធ

## បញ្ជីច្រកទ្វារព្រំដែនឆ្លងកាត់

### ប្រទេសព្រុយណេដារូសាឡឹម

- ច្រកទ្វារ សាន់ហ្គាយ ទូជូក (Sungai Tujuh)

### ព្រះរាជាណាចក្រកម្ពុជា

- ច្រកទ្វារ ប៉ោយប៉ែត (Poi Pet)
- ច្រកទ្វារ បាវិត (Bavet)
- ច្រកទ្វារ ត្រពាំងគ្រៀល (Trapeing Kreal)
- ច្រកទ្វារ កំពង់ផែអន្តរជាតិក្រុងព្រះសីហនុ (Sihanoukville International Port)

### សាធារណរដ្ឋឥណ្ឌូណេស៊ី

- ច្រកទ្វារ អេនទីកុង កាលីម៉ាន់តាន់ខាងលិច (Entikong, West Kalimantan)

### សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

- ច្រកទ្វារ ណាមប៉ាវ ខេត្តបូលីខាមសាយ (Nampaow Customs Checkpoint, Bolikhamsay Province)
- ច្រកទ្វារ អន្តរជាតិស្ពានមិត្តភាព ១ ទីក្រុងវៀងចន្ទន៍ (Friendship Bridge 1 International Customs Checkpoint, Vientiane Capital)
- ច្រកទ្វារ អន្តរជាតិស្ពានមិត្តភាព ២ ខេត្តសុវណ្ណាខេត (Friendship Bridge 2 International Customs Checkpoint, Sovannakhet Province)
- ច្រកទ្វារ អន្តរជាតិស្ពានមិត្តភាព ៤ ខេត្តបូកែវ (Friendship Bridge 3 International Customs Checkpoint, Bokeo Province)
- ច្រកទ្វារ នងណុកគៀន ខេត្តចំប៉ាសាក់ (Nongnokkien International Customs Checkpoint, Champasak Province)
- ច្រកទ្វារ ដែនសុវណ្ណ ខេត្តសុវណ្ណាខេត (Daensavanh Customs Checkpoint, Savannakhet Province)

ប្រទេសម៉ាឡេស៊ី

- ច្រកទ្វារ ប៊ូគីត កាយូ ហ៊ីតាំ ( Bukit Kayu Hitam )
- ច្រកទ្វារ តានចុង គូប៉ាំង ( Tanjong Kupang )
- ច្រកទ្វារ តេបេឌូ ( Tebedu )
- ច្រកទ្វារ ស៊ុនហ្គាយ ទូជូក ( Sungai Tujuh )
- ច្រកទ្វារ ចូហូ បារូ ( Johor Bahru )

សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា

- ច្រកទ្វារ តាឈីលេក ( Tachileik )
- ច្រកទ្វារ ម៉ៃយ៉ាវ៉ាឌី ( Myawaddy )

សាធារណរដ្ឋហ្វីលីពីន

- គ្មាន ( Nil )

សាធារណរដ្ឋសិង្ហបុរី

- ច្រកទ្វារ វូតលែន ( Woodlands Checkpoint )
- ច្រកទ្វារ តាស់ ( Tuas Checkpoint )
- ច្រកទ្វារ តំបន់ពាណិជ្ជកម្មសេរី ខេបផែល ( Keppel Free Trade Zone )
- ច្រកទ្វារ តំបន់ពាណិជ្ជកម្មសេរី ប៉ាស៊ី ប៉ានចាង ( Pasir Panjang Free Trade Zone )
- ច្រកទ្វារ តំបន់ពាណិជ្ជកម្មសេរី ជូរ៉ុង ( Jurong Free Trade Zone )
- ច្រកទ្វារ តំបន់ពាណិជ្ជកម្មសេរី សែមបាវ៉ាង ( Sembawang Free Trade Zone )
- ច្រកទ្វារ តំបន់ពាណិជ្ជកម្មសេរី ចាន់ហ្គី ( Changi Free Trade Zone )

ព្រះរាជាណាចក្រថៃឡង់ដ៍

- ច្រកទ្វារ ម៉ែសៃ ( Mae Sai Boundary Post )
- ច្រកទ្វារ ម៉ែសុត ( Mae Sot Boundary Post )
- ច្រកទ្វារ អារ៉ាន់យ៉ាប្រាថេត ( Aranyaprathet Boundary Post )
- ច្រកទ្វារ ណងខៃ ( Nong Kai Boundary Post )
- ច្រកទ្វារ សាដាវ ( Sa Dao Boundary Post )
- ច្រកទ្វារ ម៊ូកដាហាន ( Mook Da Harn Boundary Post )

- ច្រកទ្វារ ឈៀងកុង (Chiang Kong Boundary Post)

**សាធារណរដ្ឋសង្គមនិយមវៀតណាម**

- ច្រកទ្វារ កែវនឿ (Keo Nua (Cau Treo) Customs Checkpoint)
- ច្រកទ្វារ ឡាវបាវ (Lao Bao Customs Checkpoint)
- ច្រកទ្វារ ម៉ុកបៃ (Moc Bai Customs Checkpoint)

# PROTOCOL 2
# DESIGNATION OF FRONTIER POSTS

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Republic of the Union of Myanmar, the Republic of the Philippines the Republic of Singapore, the Kingdom of Thailand and the Socialist Republic of Viet Nam, Member States of the Association of Southeast Asian Nations ("ASEAN") (hereinafter referred to singularly as "Contracting Party" and collectively as "Contracting Parties");

**RECALLING** the ASEAN Framework Agreement on the Facilitation of Goods in Transit signed on 16 December 1998 in Ha Noi, Viet Nam (hereinafter referred to as "the Agreement");

**RECOGNISING** that Articles 7 and 25 thereof provide for the conclusion of implementing Protocols which shall form integral parts of the Agreement;

**DESIRING** to encourage and facilitate inter-state and transit transport operations among the Contracting Parties; and

**REITERATING** that the conclusion of this Protocol shall provide for the efficient and effective arrangement for transit trade among the Contracting Parties.

**HAVE AGREED** as follows:

CERTIFIED COPY DEPUTY SECRETARY-GENERAL, THE ASEAN SECRETARIAT asean

## ARTICLE 1
## SCOPE OF APPLICATION

1. Pursuant to paragraph 1 of Article 7 of the Agreement, the Contracting Parties hereby agree to apply the provisions of this Protocol to the frontier posts as duly designated for the clearance and examination of the means of transport and goods in transit.

2. The Contracting Parties may, with the mutual consent of the immediate neighbouring Contracting Party or Parties, allow the clearance and examination of the means of transport and goods in transit at other frontier posts, in addition to those duly designated. in an exceptional situation and on a temporary basis, as long as the terms and conditions are consistent with the principles embodied in the Agreement and this Protocol.

## ARTICLE 2
## DESIGNATION OF FRONTIER POSTS

1 The Contracting Parties hereby agree to formalise the initial respective frontier posts. as the basis for the designation of frontier posts for the purpose of this Protocol, which are listed in the Annex to this Protocol.

2. The Contracting Parties shall affirm their designated frontier posts at the time of the deposit of their Instruments of Ratification or Acceptance with the Secretary-General of ASEAN The affirmation shall be with the mutual agreement of the immediate neighbouring Contracting Party or Parties.

3. The Contracting Parties may initiate proposals for the modification of the list of the designated frontier posts from time to time. Any proposed modification by one Contracting Party shall be with the mutual agreement of the immediate neighbouring Contracting Party or Parties. Subsequent amendments to the Annex as a result of such modification shall be deposited with the Secretary-General of ASEAN who shall promptly communicate the amended Annex to the Contracting Parties.

4. The designated frontier posts established in accordance with this Protocol shall be without prejudice to any on-going territorial claims between the Contracting Parties.

## ARTICLE 3
## INSTITUTIONAL ARRANGEMENTS

1. The ASEAN Directors-General of Customs Meeting shall be the body responsible for monitoring, reviewing, coordinating and supervising all aspects relating to the effective implementation of this Protocol.

2 The ASEAN Secretariat shall provide the necessary administrative support and assistance to the ASEAN Directors-General of Customs Meeting in carrying out its functions and discharging its responsibilities under this Protocol

## ARTICLE 4
## FINAL PROVISIONS

1. This Protocol shall be deposited with the Secretary-General of ASEAN who shall promptly



CERTIFIED COPY DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT asean

furnish a certified true copy thereof to each Contracting Party.

2. This Protocol shall form an integral part of the Agreement. In the event of any inconsistency or conflict, the Agreement shall prevail over this Protocol.

3. This Protocol shall be subject to ratification or acceptance by the Contracting Parties. The Instrument of Ratification or Acceptance, including the affirmation of their designated frontier posts, shall be deposited with the Secretary-General of ASEAN who shall promptly inform each Contracting Party of such deposit. The affirmation or designation, as the case may be, of the frontier post(s) and subsequent changes and modifications to such frontier post(s) shall be accompanied by supporting documents showing the mutual agreement of the immediate neighbouring Contracting Party or Parties.

4. This Protocol shall enter into force on the sixtieth day after the deposit of the sixth Instrument of Ratification or Acceptance, and shall become effective only among the Contracting Parties that have ratified or accepted it. For each Contracting Party ratifying or accepting the Protocol after the deposit of the sixth Instrument of Ratification or Acceptance, the Protocol shall enter into force on the sixtieth day after the deposit of such Contracting Party of its Instrument of Ratification or Acceptance.

5 No reservation may be made to this Protocol either at the time of signature or ratification or acceptance.



CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean

6. Any amendment to the provisions of this Protocol, except for the amendment of the Annex as provided under paragraph 3 of Article 2 of this Protocol, shall be effected by the consent of all Contracting Parties.

**IN WITNESS WHEREOF**, the undersigned, being duly authorised to sign by their respective Governments, have signed Protocol 2 on the Designation of Frontier Posts to implement the ASEAN Framework Agreement on the Facilitation of Goods in Transit.

**DONE** at Langkawi, Malaysia on the fourth day of May in the Year Two Thousand and Eighteen, in a single copy in the English language.

For Brunei Darussalam:

**PEHIN DATO ABD RAHMAN IBRAHIM**
Minister at the Prime Minister's Office
and Minister of Finance II

For the Kingdom of Cambodia:

**NGUON SOKHA**
Secretary of State, Ministry of Economy and Finance



CERTIFIED COPY
SECRETARY GENERAL THE ASEAN SECRETARIAT
asean

For the Republic of Indonesia:

**SRI MULYANI INDRAWATI**
Minister for Finance

For the Lao People's Democratic Republic

**SILA VIENGKEO**
Deputy Minister of Finance

For Malaysia

**DATUK SERI JOHARI ABDUL GHANI**
Minister of Finance II

For the Republic of the Union of Myanmar

**Kyaw Win**
**Union Minister**
**Ministry of Planning & Finance**

For the Republic of the Philippines:

**CARLOS G. DOMINGUEZ**
Secretary of Finance

For the Republic of Singapore:

**LAWRENCE WONG**
Second Minister for Finance

For the Kingdom of Thailand:

**APISAK TANTIVORAWONG**
Minister of Finance

For the Socialist Republic of Viet Nam

**DINH TIEN DUNG**
Minister of Finance

ANNEX

**List of Designated Frontier Posts**

**Brunei Darussalam**
Sungai Tujuh

**Kingdom of Cambodia**
Poi Pet
Bavet
Trapeing Kreal
Sihanoukville International Port

**Republic of Indonesia**
Entikong West Kalimantan

**Lao People's Democratic Republic**
Nampaow Customs Checkpoint, Bolikhamsay Province
Friendship Bridge 1 International Customs Checkpoint, Vientiane Capital
Friendship Bridge 2 International Customs Checkpoint, Savannakhet Province
Friendship Bridge 4 International Customs Checkpoint, Bokeo Province
Nongnokkien International Customs Checkpoint, Champasack Province
Daensavanh Customs Checkpoint, Savannakhet Province

**Malaysia**
Bukit Kayu Hitam
Tanjong Kupang
Tebedu
Sungai Tujuh
Johor Bahru

**Republic of the Union of Myanmar**
Tachileik
Myawaddy

**Republic of the Philippines**
Nil

**Republic of Singapore**
Woodlands Checkpoint
Tuas Checkpoint
Keppel Free Trade Zone

CERTIFIED COPY DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT asean

Pasir Panjang Free Trade Zone
Jurong Free Trade Zone
Sembawang Free Trade Zone
Changi Free Trade Zone

**Kingdom of Thailand**

Mae Sai Boundary Post
Mae Sot Boundary Post
Aranyaprathet Boundary Post
Nong Kai Boundary Post
Sa Dao Boundary Post
Mook Da Harn Boundary Post
Chiang Kong Boundary Post

**Socialist Republic of Viet Nam**

Cau Treo Customs Checkpoint
Lao Bao Customs Checkpoint
Moc Bai Customs Checkpoint

CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT
asean